**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តមណ្ឌលគិរី**

សំណុំរឿងព្រហ្មទណ្ឌលេខ ២៩៥

ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០

សាលក្រមព្រហ្មទណ្ឌ

លេខ ...៨៧... "ឃ"

ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តមណ្ឌលគិរី

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នាថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ មានសមាសភាពដូចតទៅ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូង ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោកស្រី [redacted] ចៅក្រមសាលាដំបូង ជាក្រុមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូង ជាក្រុមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តមណ្ឌលគិរី

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តមណ្ឌលគិរី

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ២៩៥ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ៖

១. ឈ្មោះ [redacted] **សុផារ៉ា ហៅញ៉ាញ់** ភេទប្រុស អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ មុខរបររកស៊ីចរ ទីកន្លែងកំណើតភូ[redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្នភូមិឡាប៉ាខេ ឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី ឪពុកឈ្មោះ [redacted] សុភិន "រស់" ម្ដាយឈ្មោះ [redacted] ណាលី "រស់" ប្រពន្ធឈ្មោះ [redacted] សុភក្តិ "រស់" មានកូន០២នាក់ ជា ទីតិជន ប្រវត្តិនៃការផ្តន្ទាទោស "គ្មាន"។ (ក្រៅឃុំ)

ជាប់ចោទពីបទ **ប្រមូល និងសន្និធិផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត និងផ្តើមគំនិតលួចវត្ថុតាងព្រៃឈើ** តាមបញ្ញត្តិមាត្រា៩៨ កថាខណ្ឌ២ ចំណុច១ និងមាត្រា៩៦ កថាខណ្ឌ១ ចំណុច៣ និងមាត្រា៩៧ ចំណុច៤ នៃច្បាប់ស្តីពីព្រៃឈើ និងមាត្រា២៨ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិឡាប៉ាខេ ឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី២៨-២៩ ខែសីហា ឆ្នាំ២០២០។

២. ឈ្មោះ [redacted] ស្រស់ ភេទប្រុស អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នភូមិឡាប៉ាខេ ឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី ឪពុកឈ្មោះ [redacted] សុង "ស្លាប់" ម្ដាយឈ្មោះ [redacted] ខុម "រស់" ប្រពន្ធឈ្មោះ [redacted] ស្រីខួច មានកូន ០២នាក់ ជា ទីតិជន ប្រវត្តិនៃការផ្តន្ទាទោស "គ្មាន"។

ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១៣៨/២០ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរ។

ជាប់ចោទពីបទ៖ **លួចវត្ថុតាងព្រៃឈើ** តាមបញ្ញត្តិមាត្រា៩៧ ចំណុច៤ នៃច្បាប់ស្តីពីព្រៃឈើ ប្រព្រឹត្តនៅភូមិឡាប៉ាខេ ឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២០។

លោកស្រីមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុធារ៉ា ហៅញ៉ាញ់ និងឈ្មោះ [redacted] ស្រស់។

- បានឃើញ កំណត់ហេតុទទួលស្គាល់វត្ថុតាងចាប់យក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២០ របស់មន្ទីរយុត្តិធម៌ នៃកងរាជអាវុធហត្ថខេត្តមណ្ឌលគិរី។

- បានឃើញ ដីកាសន្និដ្ឋានស្ពាពរលេខ ៤៨២/២០ អក ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២០។

- បានឃើញ ដីកាដំណោះស្រាយលេខ ២៥២១/២០ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០។

- បានឃើញ ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខ ៣៩៥ រប/២០ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០។

- បានឃើញ ដីកាសម្រេចដាក់រឿងជំនុំជម្រះលេខ ១៦០ /២១ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១។

## អង្គហេតុដែលប្តឹងមកតុលាការ[១]

កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ ក្រុមការងារដឹកនាំដោយតំណាងអយ្យការអមសាលាដំបូងខេត្តមណ្ឌលគិរី ដោយមានការចូលរួមពីកម្លាំងចម្រុះកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានចុះឆែកឆេរទីតាំងឃ្លាំងរបស់ឈ្មោះ [redacted] សុធារ៉ា ហៅញ៉ាញ់ ដែលស្ថិតនៅភូមិឡាប៉ាខេ ឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី។ ក្នុងពេលចុះប្រតិបត្តិការ កម្លាំងចម្រុះបានចុះពិនិត្យឃើញឈើមូយគំនរចំនួន ៩២ដុំ (ស្រឡៅ ៧៥ដុំ គគីរ ១២ដុំ សុក្រម ៥ដុំ) ស្មើនឹង ២១ម៣១២៧ (ម្ភៃមួយម៉ែត្រគូបមួយរយម្ភៃប្រាំពីរ) រថយន្តសាំយ៉ុង ០១គ្រឿង គោយន្តកែច្នៃ ០១គ្រឿង រថយន្តកែច្នៃកង់១០ ចំនួន០១គ្រឿង។ ឃើញថា ឈើខាងលើនេះ គឺពុំមានលិខិតអនុញ្ញាតត្រឹមត្រូវតាមច្បាប់ឡើយ។ នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២០ ឈ្មោះ [redacted] សុធារ៉ា ហៅញ៉ាញ់ បានឱ្យឈ្មោះ ពាវ ឈ្មោះ [redacted] ស្រស់ និងបក្ខពួក បានលើកយកវត្ថុតាងចេញពីទីតាំងឃ្លាំង ហើយត្រូវកម្លាំងកងរាជអាវុធហត្ថឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ស្រស់ ចំណែកឈ្មោះ [redacted] សុធារ៉ា ហៅញ៉ាញ់ ឈ្មោះ ពាវ និងបក្ខពួករត់គេចខ្លួនបាត់អស់។

## នាពេលសវនាការ

- ជនជាប់ចោទឈ្មោះ [redacted] ស្រស់ បានឆ្លើយថា៖ កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០ វេលាម៉ោងប្រហែល ១០ព្រឹក ឈ្មោះ ពាវ ជាអ្នកជិតខាង បានពឹងខ្លួនឱ្យទៅជួយលើកម៉ាស៊ីនត្រើយនៅក្នុងឃ្លាំងរបស់ឈ្មោះ ញ៉ាញ់ ដោយមានគ្នាចំនួន ០៤នាក់ មានរូបខ្លួន ឈ្មោះ ពាវ ឈ្មោះ វណ្ណា និងម្នាក់ទៀតមិនស្គាល់ឈ្មោះ។ ពេលកំពុងលើកម៉ាស៊ីន ស្រាប់តែមានសមត្ថកិច្ចមក ហើយឈ្មោះ ពាវ ឈ្មោះ វណ្ណា និងម្នាក់ទៀតរត់គេចខ្លួន។ មូលហេតុដែលខ្លួនមិនរត់ ព្រោះខ្លួនមិនដឹងរឿង ហើយខ្លួនលើកម៉ាស៊ីនត្រើយនេះ គឺឈ្មោះ ពាវ ពឹងពាក់តែ

---

[១] មាត្រា ៣៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ប៉ុណ្ណោះ។ ខ្លួនពុំបានដឹងថា ឃ្លាំងនេះត្រូវសមត្ថកិច្ចបិទ និងហាមឃាត់មិនឱ្យប៉ះពាល់នោះទេ ព្រោះខ្លួនទើបតែមកពីធ្វើការនៅហ្គាទី ដោយសារកូនឈឺទើបខ្លួនមកសែនព្រេនឱ្យកូន។ ចំពោះឈ្មោះ ពាវ ខ្លួនមិនស្គាល់ច្បាស់ទេ គ្រាន់តែដឹងថា មានធំរាងខ្ពស់ សម្បុរស រស់នៅភូមិអូររអាម ឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី និងត្រូវជាបងថ្លៃរបស់ឈ្មោះ ញ៉ាញ់ ម្ចាស់ឃ្លាំង។ ឈ្មោះ វណ្ណា និងបុរសម្នាក់ទៀត ដែលមកជួយលើកម៉ាស៊ីនត្រើយ ខ្លួនមិនស្គាល់ទេ។ ខ្លួនគ្រាន់តែមកជួយលើកម៉ាស៊ីនត្រើយ តាមរយៈឈ្មោះ ពាវ ជាអ្នកពឹងពាក់ឱ្យមកជួយលើក ហើយការលើកនេះក៏ពុំបានទទួលប្រាក់ឈ្នួលដែរ គ្រាន់តែជាការពឹងពាក់របស់អ្នកជិតខាងតែប៉ុណ្ណោះ។ នៅពេលចូលលើកម៉ាស៊ីនត្រើយក្នុងឃ្លាំង គឺចូលតាមទ្វារក្រោយ ហើយខ្លួនពុំបានដឹងថាមានសមត្ថកិច្ចចុះបង្ក្រាប និងបិតទីតាំងនោះពីមុនទេ។ នៅពេលសមត្ថកិច្ចឃាត់ខ្លួន គឺបានដកហូត ទូរស័ព្ទមួយគ្រឿងម៉ាក NAVA ពណ៌ទឹកមាស ចំនួន ០១គ្រឿង និងម៉ាស៊ីនម៉ូតូកែច្នៃដាក់ឧបករណ៍ត្រើយ ចំនួន០២គ្រឿង។

- សាក្សីឈ្មោះ[redacted]ចំណាប់ ជាមន្ត្រីនគរបាលយុត្តិធម៌ បានឆ្លើយថា៖ កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១០ព្រឹក នៅចំណុចខ្លោងទ្វារបងឃ្លាំង ស្ថិតនៅភូមិឡាប៉ាខេ ឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី ក្រុមការងារដឹកនាំដោយតំណាងអយ្យការអមសាលាដំបូងខេត្តមណ្ឌលគិរី ដោយមានការចូលរួមពីកម្លាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងកម្លាំងអាវុធហត្ថខេត្តមណ្ឌលគិរី បានចុះឆែកឆេរឃ្លាំងស្តុកឈើរបស់ឈ្មោះ[redacted] សុធារ៉ា ហៅញ៉ាញ់ ស្រាប់តែបានឃើញឈើមួយគំនរចំនួន ៩២ដុំ រួមមានឈើស្រឡៅ គគីរ និងសុក្រម សរុបស្មើនឹង ២១ម៣១២៧ និងសម្ភារៈផ្សេងៗរួមមាន រថយន្តសាំងយ៉ុងចំនួន ០១គ្រឿង គោរយន្តកែច្នៃចំនួន ០១គ្រឿង និងរថយន្តកែច្នៃកង់១០ ចំនួន ០១គ្រឿង។ ក្រោយពីការពិនិត្យរបស់ក្រុមការងារទើបឃើញថា ឈើទាំងនោះគឺគ្មានលិខិតអនុញ្ញាតទេ ហើយក្រុមការងារក៏បានធ្វើការដកហូតវត្ថុតាងទាំងនោះ បញ្ជូនទៅរក្សាទុកនៅបរិវេណស្នាក់ការផ្នែករដ្ឋបាលព្រៃឈើកែវសីមា ដើម្បីអនុវត្តទៅតាមនីតិវិធីច្បាប់ ហើយវត្ថុមួយចំនួនទៀតដែលពុំអាចដកហូតបាន គឺរក្សាទុកនៅក្នុងឃ្លាំងដដែល ដោយមានការបិតស្លាកនៅទ្វារឃ្លាំងខាងមុខ ហើយមានសមត្ថកិច្ចនៅឃ្លាំមើល។ ស្រាប់តែនៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២០ ឈ្មោះ[redacted] ស្រស់ ត្រូវបានឈ្មោះ[redacted] សុធារ៉ា ឈ្មោះ ពាវ និងបក្ខពួកម្នាក់ទៀត បានហៅមកជួយលើកម៉ាស៊ីនត្រើយចេញពីឃ្លាំង ហើយត្រូវបានសមត្ថកិច្ចចាប់ខ្លួនឈ្មោះ ឆាយ ស្រស់ ចំណែកឈ្មោះ[redacted]សុធារ៉ា ឈ្មោះ ពាវ និងបក្ខពួកម្នាក់ទៀត បានរត់គេចខ្លួនបាត់។ នៅពេលចាប់ខ្លួនឈ្មោះ[redacted] ស្រស់ គឺបុគ្គលនេះមិនបានរត់គេចទេ ហើយបុគ្គលនេះមិនបានដឹងថា ទីតាំងឃ្លាំងនេះត្រូវបានសមត្ថកិច្ចបិតស្លាកនោះទេ។

- សាក្សីឈ្មោះ[redacted] វុទ្ធី ភេទប្រុស កើតថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៨៦ បានឆ្លើយថា៖ ខ្លួនជាប្រជាពលរដ្ឋរស់នៅឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី ហើយផ្ទះរបស់ខ្លួននៅជិតឃ្លាំងដាក់គ្រាប់ស្វាយចន្ទី ដែលជាកន្លែងកើតហេតុ។ ខ្លួនដឹងថា ទីតាំងឃ្លាំងនោះត្រូវបានជួលឱ្យជនជាតិវៀតណាម ប៉ុន្តែខ្លួនពុំដឹងថាឈ្មោះ អ្វីនោះទេ ហើយនៅថ្ងៃកើតហេតុ ក៏ខ្លួនពុំបានឃើញឈ្មោះ[redacted] ស្រស់ យកត្រើយចេញពីឃ្លាំងនោះដែរ។

- សាក្សីឈ្មោះ[redacted]បូរី ភេទប្រុស កើតថ្ងៃទី០៣ ខែឧសភា ឆ្នាំ១៩៨៩ បានឆ្លើយថា៖ ផ្ទះរបស់ខ្លួននៅជិតផ្ទះរបស់ឈ្មោះ[redacted] ស្រស់ ហើយខ្លួនដឹងថា ឈ្មោះ[redacted] ស្រស់ តែងតែទៅធ្វើការនៅហ្គាទី ដោយស៊ី

ឈ្នួលដកដំឡូង ឬធ្វើស្មៅឱ្យគេ ហើយគាត់ចេញពីផ្ទះពេលព្រឹក ហើយត្រឡប់មកវិញនៅពេលល្ងាច។ គាត់គឺជាមនុស្សស្លូតបូត មិនធ្លាប់ប្រព្រឹត្តបទល្មើសអ្វីទេ ហើយគាត់ក៏ពុំធ្លាប់រកស៊ីឈើដែរ។

- សាក្សីឈ្មោះ [redacted] សុភក្តិ ភេទស្រី កើតថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៩១ បានឆ្លើយថា៖ នៅថ្ងៃកើតហេតុខ្លួននៅផ្ទះម្តាយរបស់ខ្លួន ស្ថិតនៅភូមិស្រែព្រះ ហើយខ្លួនបានឮគេប្រាប់ថា សមត្ថកិច្ចចាប់ខ្លួនឈ្មោះ [redacted] ស្រស់ តែមិនដឹងថាពាក់ព័ន្ធរឿងអ្វីនោះទេ។ ផ្ទះរបស់ខ្លួននៅជិតផ្ទះរបស់ឈ្មោះ [redacted] ស្រស់ ហើយខ្លួនដឹងថាឈ្មោះ [redacted] ស្រស់ គឺជាមេគ្រួសារ ហើយគ្រួសាររបស់គាត់ពឹងផ្អែកលើគាត់ទាំងស្រុង ក្នុងការរកប្រាក់ដើម្បីផ្គត់ផ្គង់គ្រួសារ។

- **តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំដូចតទៅ៖** ក្រោយពីបានពិភាក្សាដេញដោលរួចឃើញថា តាមចម្លើយរបស់សាក្សីជាមន្ត្រីកងរាជអាវុធហត្ថបានបញ្ជាក់ថា នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ សមត្ថកិច្ចបានចុះឆែកឆេរឃ្លាំងដែលមានទីតាំងនៅភូមិឡាប៉ាខេ ឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី ហើយបានដកហូតវត្ថុតាងមួយចំនួន យកមករក្សាទុកនៅបរិវេណស្នាក់ការផ្នែករដ្ឋបាលព្រៃឈើកែវសីមា ហើយវត្ថុមួយចំនួនដែលពុំអាចប្រមូលយកបាន គឺរក្សាទុកនៅក្នុងឃ្លាំង។ ស្រាប់តែនៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២០ ឈ្មោះ [redacted] សុធារ៉ា ហៅញ៉ាញ់ បានឱ្យឈ្មោះ [redacted] ស្រស់ ឈ្មោះ ពាវ និងបក្ខពួក យកគ្រឿយដែលនៅក្នុងឃ្លាំង។ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សុធារ៉ា ហៅញ៉ាញ់ បង្កើតបានជាធាតុផ្សំបទល្មើស ផ្តើមគំនិតក្នុងអំពើលួចវត្ថុតាងព្រៃឈើ តាមបញ្ញត្តិមាត្រា៩៧ ចំណុច៤ នៃច្បាប់ស្តីពីព្រៃឈើ និងមាត្រា២៨ នៃក្រមព្រហ្មទណ្ឌ។ ម្យ៉ាងទៀត ជនជាប់ចោទរូបនេះ បានប្រមូល និងសន្និធិផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត តាមបញ្ញត្តិមាត្រា៩៨ កថាខណ្ឌ២ ចំណុច១ និងមាត្រា៩៦ កថាខណ្ឌ១ ចំណុច៣ នៃច្បាប់ស្តីពីព្រៃឈើ ដូច្នេះប្តឹងសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។ ដោយឡែកជនជាប់ចោទឈ្មោះ [redacted] ស្រស់ ដែលបានចូលទៅយកម៉ាស៊ីនគ្រឿយ តាមរយៈការពឹងពាក់ពីឈ្មោះ ពាវ ដោយពុំបានដឹងថា វត្ថុទាំងនោះត្រូវបានសមត្ថកិច្ចដកហូត គឺពុំមានចេតនាក្នុងការប្រព្រឹត្តបទល្មើសឡើយ ដូច្នេះស្នើសុំក្រុមប្រឹក្សាជំនុំជម្រះពិចារណា និងសម្រេចឱ្យរួចផុតបទចោទ។

- **មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ធ្វើសេចក្តីសន្និដ្ឋានស្នើសុំដូចតទៅ៖** ក្រោយពីបានពិភាក្សាដេញដោលរួចឃើញថា កូនក្តីរបស់ខ្លួនឈ្មោះ [redacted] ស្រស់ គ្មានចេតនាក្នុងការប្រព្រឹត្តបទល្មើសនោះទេ ដោយកូនក្តីខ្លួនពុំបានដឹងថា សមត្ថកិច្ចបានចុះបង្ក្រាបបទល្មើស ហើយបិតទីតាំងឃ្លាំងនោះទេ ដោយសារតែកូនក្តីខ្លួនចេញទៅស៊ីឈ្នួលគេនៅខាងក្រៅ។ ម្យ៉ាងទៀតនៅពេលសមត្ថកិច្ចធ្វើការឃាត់ខ្លួនកូនក្តីរបស់ខ្លួន គឺគាត់ពុំបានរត់គេចឡើយ ដូច្នេះស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចឱ្យកូនក្តីខ្លួនរួចផុតបទចោទ និងដោះលែងឱ្យមានសេរីភាព។

- **សម្តីចុងក្រោយរបស់ជនជាប់ចោទ៖** ជាប់ចោទឈ្មោះ [redacted] ស្រស់ ស្នើសុំទៅក្រុមជំនុំជម្រះដោះលែងឱ្យមានសេរីភាពវិញ។

- ផ្អែកតាមលទ្ធផលនៃកិច្ចពិភាក្សាដេញដោល។

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ។

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានស្នើសុំរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ។

Scanned with CamScanner

- ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ។
- ក្រោយពីបានពិនិត្យឯកសារភស្តុតាងក្នុងសំណុំរឿងចប់សព្វគ្រប់។

**សំអាងហេតុ**

១. កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ កម្លាំងសមត្ថកិច្ចចម្រុះដែលដឹកនាំដោយតំណាងអយ្យការ បាន ចុះឆែកឆេរទីតាំងឃ្លាំងរបស់ឈ្មោះ [redacted] សុធារ៉ា ហៅញ៉ាញ់ ដែលមានទីតាំងស្ថិតនៅភូមិឡាប៉ាខេ ឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី ប្រទះឃើញឈើចំនួន ៩២ដុំ (ស្រឡៅ ៧៥ដុំ គគីរ ១២ដុំ សុក្រម ៥ដុំ) ស្មើនឹង ២១ម$^{៣}$១២៧ (ម្ភៃមួយម៉ែត្រគ្រីគុន មួយរយម្ភៃប្រាំពីរ) រថយន្តស៊ុំយ៉ុង ០១គ្រឿង គោយន្តកែច្នៃ ០១គ្រឿង រថយន្តកែច្នៃកង់១០ ចំនួន០១គ្រឿង។ បន្ទាប់ពីធ្វើការពិនិត្យឃើញថា ឈើខាងលើនេះពុំមានលិខិតអនុញ្ញាត ក្រុមសមត្ថកិច្ចបានធ្វើការដកហូតឈើ និងវត្ថុតាងខាងលើ បញ្ជូនទៅរក្សាទុកនៅក្នុងបរិវេណស្នាក់ការផ្នែកកែវសីមា ហើយបានសម្រេចបិតទីតាំងឃ្លាំងតែម្តង។ នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២០ ឈ្មោះ [redacted] សុធារ៉ា ហៅញ៉ាញ់ បានឲ្យឈ្មោះ ពាវ ឈ្មោះ [redacted] ស្រស់ និងបក្ខពួក មកលើកម៉ាស៊ីនម៉ូតូដែលមានភ្ជាប់ត្រើយ ចេញពីក្នុងឃ្លាំង តែត្រូវសមត្ថកិច្ចចាប់ខ្លួនឈ្មោះ [redacted] ស្រស់ ចំណែកអ្នកផ្សេងទៀតបានរត់គេចខ្លួនបាត់។

២. តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស្រស់ បានបញ្ជាក់ថា ខ្លួនគ្រាន់តែមកជួយលើកម៉ាស៊ីនត្រើយតាមការពឹងពាក់របស់ឈ្មោះ ពាវ ប៉ុណ្ណោះ ហើយខ្លួនពុំបានដឹងថា ទីតាំងឃ្លាំងត្រូវបានបិត ហើយវត្ថុដែលមាននៅក្នុងឃ្លាំងត្រូវបានសមត្ថកិច្ចដកហូតនោះទេ ដោយហេតុថាខ្លួនទៅស៊ីឈ្នួលដកដំឡូង និងជម្រះស្មៅឲ្យគេនៅហ្គាទី។ ម្យ៉ាងទៀតសាក្សីដែលជាមន្ត្រីនគរបាលយុត្តិធម៌ក៏បានបញ្ជាក់ដែរថា នៅពេលដែលសមត្ថកិច្ចចាប់ខ្លួន ជនជាប់ចោទមិនបានរត់គេចនោះទេ ហើយក៏មិនបានដឹងថាសមត្ថកិច្ចបានបិតទីតាំងឃ្លាំងនោះទេ។ ផ្អែកតាមចម្លើយទាំងនោះ តុលាការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ស្រស់ ពុំមានចេតនាក្នុងការប្រព្រឹត្តបទល្មើសឡើយ។ អនុលោមតាមមាត្រា៤ នៃក្រមព្រហ្មទណ្ឌ បានបញ្ញត្តិថា **"ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត"**។ ដូច្នេះអំពើរបស់ជនជាប់ចោទមិនមែនជាបទល្មើសទេ គប្បីសម្រេចឲ្យជនជាប់ចោទឈ្មោះ ឆាយ ស្រស់ រួចខ្លួនពីបទចោទ តាមបញ្ញត្តិមាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣. អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សុធារ៉ា ហៅញ៉ាញ់ ដែលបាន ប្រមូល និងសន្និធិផល អនុផលព្រៃឈើ ដោយគ្មានលិខិតអនុញ្ញាត គឺជាអំពើដែលត្រូវបានច្បាប់ហាមឃាត់ ហើយជាបទល្មើសព្រហ្មទណ្ឌតាមបញ្ញត្តិមាត្រា៩៨ កថាខណ្ឌ២ ចំណុច១ និងមាត្រា៩៦ កថាខណ្ឌ១ ចំណុច៣ នៃច្បាប់ស្តីពីព្រៃឈើ។ ម្យ៉ាងទៀត ជនជាប់ចោទបានណែនាំ ឬបញ្ជាឲ្យអ្នកដទៃ លួចយកវត្ថុតាងដែលសមត្ថកិច្ចបានដកហូត គឺជាអំពើផ្តើមគំនិតលួចវត្ថុតាងព្រៃឈើ តាមបញ្ញត្តិមាត្រា៩៧ ចំណុច៤ នៃច្បាប់ស្តីពីព្រៃឈើ និងមាត្រា២៨ នៃក្រមព្រហ្មទណ្ឌ។ ជាពិសេស អំពើទាំងនេះបានធ្វើឲ្យបាត់បង់ព្រៃឈើរបស់រដ្ឋ ហើយធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយល្អរបស់សង្គម។

៤. ជនជាប់ចោទឈ្មោះ [redacted] សុធារ៉ា ជានីតិជន មាននីតិសម្បទាគ្រប់គ្រាន់ ដោយពុំមានសញ្ញាណាមួយ ដែលនាំឲ្យមានមន្ទិលសង្ស័យថាជននេះមានបញ្ហាវិបល្លាសស្មារតីក្នុងពេលប្រព្រឹត្តល្មើសឡើយ។ ជនជាប់-ចោទជាសមត្ថជន ដែលមានការពិចារណា ព្រមទាំងយល់ដឹងអំពីផលវិបាកដែលកើតចេញពីអំពើរបស់ខ្លួន ដែលស្ថិតនៅក្នុងលក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌ។

Scanned with CamScanner

៥. តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងចោទប្រកាន់ជនជាប់ចោទឈ្មោះ [redacted] សុផារ៉ា ហៅញ៉ាញ់ **ពីបទ ប្រមូល និងសន្និធិផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត និងផ្តើមគំនិតលួចវត្ថុតាងព្រៃឈើ** តាមបញ្ញត្តិមាត្រា៩៨ កថាខណ្ឌ២ ចំណុច១ និងមាត្រា៩៦ កថាខណ្ឌ១ ចំណុច៣ និងមាត្រា៩៧ ចំណុច៤ នៃច្បាប់ស្តីពីព្រៃឈើ និងមាត្រា២៨ នៃក្រមព្រហ្មទណ្ឌ។ ចំណែកជនជាប់ចោទឈ្មោះ [redacted] ស្រស់ តំណាងអយ្យការស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះពិចារណា និងសម្រេចឱ្យរួចផុតបទចោទ ដោយហេតុថា ជនជាប់ចោទរូបនេះពុំមានចេតនាក្នុងការប្រព្រឹត្តល្មើសឡើយ។ ការប្តឹងសុំនេះតុលាការយល់ឃើញថា មានភាពត្រឹមត្រូវដែលអាចលើកយកមកពិចារណា និងសម្រេចតាមការប្តឹងសុំ។

៦. តាមសេចក្តីសន្និដ្ឋានស្នើសុំរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ដែលបានស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះ សម្រេចឱ្យកូនក្តីខ្លួនឈ្មោះ [redacted] ស្រស់ រួចផុតបទចោទ និងដោះលែងឱ្យមានសេរីភាព ដោយហេតុថាកូនក្តីខ្លួនពុំបានដឹងថាសមត្ថកិច្ចចុះបង្ក្រាបបទល្មើស ហើយបិតទីតាំងឃ្លាំងនោះទេ ហើយកូនក្តីខ្លួនក៏ពុំបានរត់គេចខ្លួនដែរ។ ការស្នើសុំនេះមានភាពត្រឹមត្រូវ ដែលអាចលើកយកមកពិចារណា និងសម្រេចតាមការស្នើសុំ។

៧. មានធាតុផ្សំបទល្មើស និងមានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សុផារ៉ា ហៅញ៉ាញ់ **ពីបទ ប្រមូល និងសន្និធិផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត និងផ្តើមគំនិតលួចវត្ថុតាងព្រៃឈើ** តាមបញ្ញត្តិមាត្រា៩៨ កថាខណ្ឌ២ ចំណុច១ និងមាត្រា៩៦ កថាខណ្ឌ១ ចំណុច៣ និងមាត្រា៩៧ ចំណុច៤ នៃច្បាប់ស្តីពីព្រៃឈើ និងមាត្រា២៨ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិឡាប៉ាខេ ឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី២៨-២៩ ខែសីហា ឆ្នាំ២០២០។

៨. វត្ថុតាង ឈើចំនួន ៩២ដុំ (ស្រឡៅ ៧៥ដុំ គគីរ ១២ដុំ សុក្រម ៥ដុំ) ស្មើនឹង ២១ម$^{៣}$១២៧ (ម្ភៃមួយម៉ែត្រគ្រីគុប មួយរយម្ភៃប្រាំពីរ) រថយន្តសុំយ៉ុង ០១គ្រឿង គោយន្តកែច្នៃ ០១គ្រឿង រថយន្តកែច្នៃកង់១០ ចំនួន ០១គ្រឿង និងម៉ាស៊ីនម៉ូតូកែច្នៃដាក់ឧបករណ៍ត្រើយ ចំនួន ០២គ្រឿង គឺជាផល អនុផលព្រៃឈើដែលជាវត្ថុតាងពិតប្រាកដនៃបទល្មើស និងជាសម្ភារៈបរិក្ខា និងមធ្យោបាយដឹកជញ្ជូនដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស តាមបញ្ញត្តិមាត្រា៨២ នៃច្បាប់ស្តីពីព្រៃឈើ ហើយជាកម្មវត្ថុនៃការរឹបអូសតាមបញ្ញត្តិមាត្រា៩៧ និងមាត្រា៩៨ នៃច្បាប់ស្តីពីព្រៃឈើ។

៩. ផ្អែកតាមសំអាងហេតុចំណុចទី២ និងទី៥ ខាងលើ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ស្រស់ មិនមែនជាបទល្មើស គប្បីតុលាការសម្រេចដោះលែងជនជាប់ចោទរូបនេះ ឱ្យមានសេរីភាពវិញ ដោយអនុវត្តតាមបញ្ញត្តិមាត្រា៣៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

១០. អនុលោមតាមមាត្រា២៤៧ថ្មី ចៅក្រមស៊ើបសួរបិតការស៊ើបសួរតាមដីកាដំណោះស្រាយ ដូច្នេះដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ គឺជាការបញ្ចប់សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ។

## សេចក្តីសម្រេច

១. ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] សុផារ៉ា ហៅញ៉ាញ់ ភេទប្រុស អាយុ៣៤ឆ្នាំ ដាក់ពន្ធនាគាររយៈពេល ០៥(ប្រាំ)ឆ្នាំ ពីបទ ប្រមូល និងសន្និធិផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត និងផ្តើមគំនិតលួចវត្ថុតាងព្រៃឈើ តាមបញ្ញត្តិមាត្រា៩៨ កថាខណ្ឌ២ ចំណុច១ និងមាត្រា៩៦ កថាខណ្ឌ១ ចំណុច៣ និង

Scanned with CamScanner

មាត្រា៩៧ ចំណុច៤ នៃច្បាប់ស្តីពីព្រៃឈើ និងមាត្រា២៨ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិឡាប៉ាខេ ឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី២៨-២៩ ខែសីហា ឆ្នាំ២០២០។

២. ឲ្យជនជាប់ចោទឈ្មោះ [redacted] ស្រស់ ភេទប្រុស អាយុ៣៤ឆ្នាំ រួចខ្លួនពីបទចោទ តាមបញ្ញត្តិមាត្រា ៣៥០ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ពីបទ លួចវត្ថុតាងព្រៃឈើ តាមបញ្ញត្តិមាត្រា៩៧ ចំណុច៤ នៃច្បាប់ស្តីពីព្រៃឈើ ប្រព្រឹត្តនៅភូមិឡាប៉ាខេ ឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២០។

៣. ដោះលែងជនជាប់ចោទឈ្មោះ [redacted] ស្រស់ ភេទប្រុស អាយុ៣៤ឆ្នាំ ឲ្យមានសេរីភាព តាមបញ្ញត្តិមាត្រា៣៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤. រឹបអូសវត្ថុតាងជាសម្បត្តិរដ្ឋមាន៖ ឈើចំនួន ៩២ដុំ (ស្រឡៅ ៧៥ដុំ គគីរ ១២ដុំ សុក្រម ៥ដុំ) ស្មើនឹង ២១ម៉ែត្រគូប១២៧ (ម្ភៃមួយម៉ែត្រគ្រីគុន មួយរយម្ភៃប្រាំពីរ) រថយន្តស៊ាំយ៉ុង ០១គ្រឿង គោយន្តកែច្នៃ ០១គ្រឿង រថយន្តកែច្នៃកង់១០ ចំនួន០១គ្រឿង និងម៉ាស៊ីនម៉ូតូកែច្នៃដាក់ឧបករណ៍គ្រើយ ចំនួន ០២គ្រឿង។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ស្រស់ តែកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សុធារ៉ា ហៅញ៉ាញ់។

ភាគីមានសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ ពុធ ៨កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

មណ្ឌលគិរី,ថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

Scanned with CamScanner